**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៧៥២៧ /១២៣ កសក.អល

ថ្ងៃព្រហស្បតិ៍ ២រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៧ ឆ្នាំ២០២៣

## ជម្រាបមក

## លោកស្រីប្រធានក្រុមហ៊ុន សលីដ អ៉ក់

**កម្មវត្ថុ ៖** ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការបោះពុម្ពឯកសារបច្ចេកទេសចិញ្ចឹមសត្វ ជំងឺឆ្លងសត្វ និងខិត្តប័ណ្ណផ្សព្វផ្សាយពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

**យោង ៖** កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់គណៈកម្មាធិការលទ្ធកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបោះពុម្ពឯកសារបច្ចេកទេសចិញ្ចឹមសត្វ ជំងឺឆ្លងសត្វ និងខិត្តប័ណ្ណផ្សព្វផ្សាយពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកស្រីប្រធាន** ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (គណៈកម្មាធិការលទ្ធកម្ម) បានសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុនរបស់លោកស្រី ដើម្បីធ្វើការបោះពុម្ពឯកសារបច្ចេកទេសចិញ្ចឹមសត្វ ជំងឺឆ្លងសត្វ និងខិត្តប័ណ្ណផ្សព្វផ្សាយពាក់ព័ន្ធនឹងសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងឆ្នាំ២០២៣ ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន១៨២ ៤៥០ ០០០៛ (មួយរយប៉ែតសិបពីរលានបួនរយសែសិបពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យហេតុនេះ សូម **លោកស្រីប្រធាន** ជ្រាបជាព័ត៌មានតាមការគួរ។

សូម **លោកស្រីប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ក្រុមហ៊ុន ភី អេស ឌី អិន ខមមើស
- ក្រុមហ៊ុន ណៃ ស្រេង អ៊ីមផត អិចផត
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ